# ឧស្សាហកម្មកាត់ដេរកម្ពុជាឱតខំតស៊ូ នៅពេលមានឱនភាពសេដ្ឋកិច្ចសកលលោក

## ឱនភាពសេដ្ឋកិច្ចសកលលោក

នៅ ក្នុង ឆ្នាំ ២០០៨ សេដ្ឋកិច្ចសកលលោកបានធ្លាក់ចូលទៅក្នុងស្ថានភាពឱនភាព។ ជាលទ្ធផល តម្រូវការនៅសហរដ្ឋអាមេរិក និង អឺរ៉ុប ដែលជាទីផ្សារផលិតផលវាយនភ័ណ្ឌដ៏ធំបំផុតក្នុងពិភពលោក បាន ធ្លាក់ ចុះ យ៉ាង គំហុក។[១] ស្ថិតិ ពាណិជ្ជកម្ម របស់សហរដ្ឋអាមេរិកបង្ហាញថាវិស័យកាត់ដេររបស់ប្រទេសកម្ពុជាស្ថិតនៅ ក្នុង ចំណោមវិស័យ នានា ដែល រង ផល ប៉ះពាល់ ធ្ងន់ ធ្ងរ ជាងគេ នៅក្នុងតំបន់ (សូមមើលរូបភាពទី ១)។

រូបភាពទី ១: ការនាំចូលសម្លៀកបំពាក់របស់សហរដ្ឋអាមេរិក បែងចែកតាមប្រទេស ពីខែ ធ្នូ ឆ្នាំ ២០០៨ ដល់ខែ ធ្នូ ឆ្នាំ ២០០៩ (បម្រែបម្រួលគិតជា %)[២]




ការកើនឡើងនូវការប្រកួតប្រជែង ផលិតភាពនៅទាប រយៈពេលរង់ចាំ ការ ផលិត យូរ និង ការចំណាយ ខ្ពស់ លើ ហេដ្ឋារចនាសម្ព័ន្ធ អាច និយាយ បាន ថា គឺ ជា មូលហេតុ សំខាន់ៗ បង្កការ លំបាក មួយ ចំនួន ដែល ប្រទេស នេះ កំពុង ជួប ប្រទះ ក្នុងពេលដែលកំពុងមានវិបត្តិនេះកើតឡើង។

## ផលប៉ះពាល់តាមវិស័យ

ការ នាំ ចេញ សំខាន់ របស់ ប្រទេស កម្ពុជា គឺ ការ នាំចេញ សម្លៀកបំពាក់ ដែលមានប្រមាណ ៧០% នៃតម្លៃនាំចេញសរុប។ នៅក្នុងឆ្នាំ ២០០៨ ការ នាំចេញ សម្លៀក បំពាក់ កើន ឡើង ដល់ ២,៩៨ ពាន់លានដុល្លា ពោលគឺកើនពី ២,៨៧ ពាន់លានដុល្លា នៅក្នុងឆ្នាំ ២០០៧។ ប៉ុន្តែ នៅក្នុងឆ្នាំ ២០០៨ កំណើននេះ បាន ចុះ ខ្សោយ ដោយ សារ ផល ប៉ះ ពាល់ ដំបូងៗ នៃវិបត្តិនេះ ដែល បាន កើត មានឡើងអំឡុងត្រីមាសទីពក្នុងឆ្នាំនោះ។[៣] ដោយសារតែការធ្លាក់ចុះយ៉ាងឆាប់រហ័សនេះនៅតែបន្តកើតមាននៅអឺរ៉ុប និងសហរដ្ឋអាមេរិក ការនាំចេញសម្លៀកបំពាក់របស់ប្រទេស កម្ពុជា បាន ថយ ចុះ ចំនួន ១៨,៩% នៅ ក្នុងឆ្នាំ ២០០៩ (សូមមើលរូបភាពទី ២)។

រូបភាពទី ២: ការនាំចេញសម្លៀកបំពាក់របស់ប្រទេសកម្ពុជា ២០០១_២០០៩ (គិតជាលានដុល្លាសហរដ្ឋអាមេរិក)[៤]




---

[១] សម្លៀកបំពាក់ផលិតក្នុងប្រទេសកម្ពុជាចំនួន ៩០% ត្រូវបាននាំចេញទៅសហរដ្ឋអាមេរិក និងអឺរ៉ុប

[២] ក្រសួងពាណិជ្ជកម្មសហរដ្ឋអាមេរិក ២០១០: ផ្នែក ពាណិជ្ជកម្ម អន្តរជាតិ ការិយាល័យវាយនភ័ណ្ឌ និងសម្លៀកបំពាក់ (http://otexa.ita.doc.gov/MSRCTRY.htm, កែសម្រួលចុងក្រោយនៅថ្ងៃទី៤ ខែ កុម្ភៈ ឆ្នាំ ២០១០ អាចចូលមើលថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១០)

[៣] UNDP ២០០៩: ឱនភាព សេដ្ឋកិច្ច សកលលោក: ឱកាស ឬវិបត្តិ? ខែ វិច្ឆិកា ឆ្នាំ ២០០៩, ទំព័រទី ២៣

[៤] ក្រសួងពាណិជ្ជកម្ម ២០១០

ទិន្នន័យអំពីរោងចក្រដែលបានបិទទ្វារបង្ហាញឱ្យឃើញកាន់តែច្បាស់អំពី ផល ប៉ះ ពាល់ របស់ វិបត្តិ នេះ។ នៅដើមខែ វិច្ឆិកា ឆ្នាំ ២០០៩ ចរន្តនៃការបិទទ្វាររោងចក្របានបញ្ចប់និន្នាការកំណើនថេរ (សូមមើលរូបភាពទី ៣)។ នៅក្នុងរយៈពេលមួយឆ្នាំ ចំនួនរោងចក្រ ដំណើរការ បាន ថយចុះ ពី ៣១៣ ដែល ជា ចំនួន ច្រើន បំផុត នៅ ក្នុង ខែ តុលា ឆ្នាំ ២០០៨ មក នៅ ត្រឹម ២៤១ រោងចក្រ នៅក្នុងខែ វិច្ឆកា ឆ្នាំ ២០០៩ ហើយរោងចក្រដែលនៅបើកទ្វារភាគច្រើនដំណើរការត្រឹមតែ ៦០-៧០% តាមសមត្ថភាពរោងចក្ររបស់ពួកគេ។[៥/៦]

រូបភាពទី ៣: ចំនួនរោងចក្រពីឆ្នាំ ២០០០-២០០៩ (គិតជាមធ្យមតាមឆ្នាំ)[៧]




យោងតាមក្រសួងពាណិជ្ជកម្ម ការបិទទ្វាររោងចក្រទាំងនេះបានធ្វើឱ្យ កម្មករ និយោជិត ចំនួន ៧៥,៥០០ នាក់ បាត់ បង់ ការងារ ឬស្មើនឹង ២១% នៃកម្លាំងពលកម្មសរុប។ ចន្លោះពីខែ កញ្ញា ឆ្នាំ ២០០៨ ដល់ ខែ តុលា ឆ្នាំ ២០០៩ កម្លាំង ពលកម្ម ក្នុងឧស្សាហកម្មកាត់ដេរកម្ពុជាថយចុះពី ៣៥២,៩៥៥ នាក់មកនៅ ២៧៨,៣៩៨ នាក់ (សូមមើលរូបភាពទី ៤)។ លើសពីនេះទៅទៀត រោងចក្រជាច្រើនបានព្យួរការងារជាបណ្ដោះអាសន្ន។

រូបភាពទី ៤: ការវិវឌ្ឍន៍នៃកម្លាំងពលកម្មពីឆ្នាំ ២០០០ ដល់ ២០០៩ (គិតជាពាន់នាក់ ចំនួនមធ្យមតាមឆ្នាំ)[៨]




ដោយសារតែកម្មករនិយោជិតកាត់ដេរភាគច្រើនលើសលុបគឺជាស្ត្រី និងមានប្រភពពីតំបន់ជនបទក្រីក្ររបស់ប្រទេស វិបត្តិសកលលោកនេះបានបង្កឱ្យមានផលប៉ះពាល់ដល់ប្រជាជនដែលងាយរងគ្រោះបំផុតមួយចំនួន។ លទ្ធផលបឋមនៃការសិក្សានានាបង្ហាញថា កម្មករនិយោជិតកាត់ដេរត្រូវបង្ខំចិត្តកាត់បន្ថយការចំណាយរបស់ពួកគេលើម្ហូបអាហារ និងលើការថែទាំសុខភាព នៅក្នុងពេលកំពុងមានវិបត្តិនេះ។

## ទស្សនះវិស័យ និងការឆ្លើយតប

រូបភាពដែលបានបង្ហាញខាងលើបង្ហាញពីទិដ្ឋភាពអន់ថយរបស់វិស័យនេះ។ ប៉ុន្តែ ទិន្នន័យនៅត្រីមាសចុងក្រោយក្នុងឆ្នាំ ២០០៩ និងដើមខែ មករា ឆ្នាំ ២០១០ បង្ហាញថា ឧស្សាហកម្មនេះបានធ្លាក់ដល់កម្រិតទាបបំផុត ហើយកំពុងចាប់ផ្ដើមងើបឡើងវិញបន្តិចម្ដងៗ។ ចំនួនរោងចក្រ និងកម្មករនិយោជិតហាក់បីដូចជានៅថេរ (សូម មើល រូបភាព ទី ៥ និង ទី ៦) ហើយ នៅ ក្នុង ខែ មករា ឆ្នាំ ២០១០ ជា លើក ទី ១ ចាប់ តាំង ពី ខែ ធ្នូ ឆ្នាំ ២០០៨ មក ការ នាំ ចេញ សម្លៀក បំពាក់ បាន កើនឡើងបន្តិច (៧,៣%) បើប្រៀបធៀបជាមួយខែដដែលនេះ កាលពីឆ្នាំមុន។

[៥] ibid.
[៦] UNDP ២០០៩, ទំព័រទី ២៣
[៧] ក្រសួងពាណិជ្ជកម្ម ២០១០
[៨] ក្រសួងពាណិជ្ជកម្ម ២០១០

រូបភាពទី ៥: ចំនួនរោងចក្រ ពីខែ ឧសភា ឆ្នាំ ២០០៩ ដល់ខែ មករា ឆ្នាំ ២០១០[៩]




នៅក្នុងរយៈពេលវែង វិបត្តិនេះនេះអាចជួយពង្រឹងឧស្សាហកម្មនេះ តាមរយៈការបង្ហាញឱ្យឃើញពីតម្រូវការ ដើម្បីបង្កើនផលិតភាព និងសមត្ថភាព ប្រកួតប្រជែង ហើយ ក្នុង ពេលជាមួយ គ្នា អាច រក្សា បាននូវលក្ខខណ្ឌការងារសមរម្យ។

រូបភាពទី ៦:ការវិវឌ្ឍន៍នៃកម្លាំងពលកម្ម ពីខែ ឧសភា ឆ្នាំ ២០០៩ ដល់ខែ មករា ឆ្នាំ ២០១០ (គិតជាពាន់នាក់)[១០]




រដ្ឋាភិបាល និង ដៃគូ ឧស្សាហកម្ម កំពុង ខិតខំ កាត់បន្ថយ ផលប៉ះពាល់អវិជ្ជមាន នៃវិបត្តិនេះដែលកើតមានមកលើកម្មករនិយោជិត កាត់ដេរ និងធានាឱ្យឧស្សាហកម្មនេះងើបឡើងវិញ ព្រមទាំងអាច ធានាបាននូវការរីកចម្រើនរយៈពេលវែង នៅក្នុងបរិយាកាសទីផ្សារ ដែលកាន់តែ មាន ការ ប្រកួត ប្រជែង ច្រើន ឡើងៗ។ បច្ចុប្បន្ន នេះ *រោងចក្រ កាន់ តែ ប្រសើរ នៅ កម្ពុជា* កំពុង គាំទ្រ ដល់ គោលដៅ ទាំងនេះ តាមរយៈ :

- ការសិក្សា តាមដាន ជាមួយនឹង កម្មករ និយោជិត ចំនួន ២០០០ នាក់ នៅក្នុងរយៈពេល ៦ ខែ
- ការ បណ្តុះបណ្តាល កម្មករ និយោជិត និង និយោជក អំពី អន្តរកាលដែលមានការទទួលខុសត្រូវចំពោះសង្គម
- វិធានការ បង្កើត ទំនុកចិត្ត និង កសាង ជំនាញ លើ ឧស្សាហកម្ម នេះ ដូចជា ព្រឹត្តិការណ៍ តស៊ូ មតិ និង ការ បណ្តុះបណ្តាល ជាដើម។

---

[៩] ibid.

[១០] ibid.